ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខ៖២៤៤ ចុះថ្ងៃទី១៥.៣.២០២១

សញ្ញាណរឿងក្តី៖ ប្តឹងសុំផ្តាច់ចំណងអាពាហ៍ពិពាហ៍

សាលក្រមលេខ៖១២៤"ណ" ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២១

# ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈ នៅថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០២១ លើសំណុំរឿងរដ្ឋប្បវេណីលេខ: ២៤៤ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២១។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

សាលាដំបូងខេត្តកណ្តាល បានចេញសាលក្រមដែលមានគូភាគីដូចខាងក្រោម:

-ដើមចោទឈ្មោះ [redacted] អាន ភេទប្រុស អាយុ ៤៥ ឆ្នាំ មុខរបរ យោធា សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ[redacted] ឪពុកឈ្មោះ [redacted] ធូ (រ/ស) ម្តាយឈ្មោះ [redacted] សាម្លួន (រ/ស) ប្រពន្ធឈ្មោះ [redacted] ផល្លា (រស់) មានកូន ០២ នាក់ ។

-មានតំណាងដោយអាណត្តិឱ្យដើមចោទ៖

-លោក [redacted] ភេទប្រុស អត្តលេខ:៨៣៦ សញ្ជាតិខ្មែរ ជាសមាជិកគណៈមេធាវី [redacted] ។

-ចុងចម្លើយឈ្មោះ [redacted] ផល្លា ភេទស្រី អាយុ ៥០ ឆ្នាំ មុខរបរ អ៊ុកសក់ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិផ្ទះ[redacted] ឪពុកឈ្មោះ [redacted] អាយ (រ/ស) ម្តាយឈ្មោះ [redacted] ណយ (រ/ស) ប្តីឈ្មោះ [redacted] អាន (រស់) មានកូន ០២ នាក់ ។

-មានតំណាងដោយអាណត្តិឱ្យចុងចម្លើយ:

-លោក [redacted] ភេទប្រុស អត្តលេខ:១៦៨៩ សញ្ជាតិខ្មែរ ជាសមាជិកគណៈមេធាវី [redacted] ។

-លោក [redacted] ភេទប្រុស អត្តលេខ: [redacted] ជាសមាជិកគណៈមេធាវី [redacted] មានអាសយដ្ឋានផ្ទះលេខ [redacted] ។



Scanned with CamScanner

## **អង្គហេតុ និងចំណុចវិវាទ**

១.សាលក្រមដែលទាមទារដោយដើមចោទ៖

-សុំផ្តាច់ចំណងអាពាហ៍ពិពាហ៍ពីប្រពន្ធឈ្មោះ [redacted] ផល្លា តាមច្បាប់ ។

-ប្រគល់ឲ្យចុងចម្លើយមានសិទ្ធិគ្រប់គ្រងកូនចំនួន២នាក់ ទី១ ឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស អាយុ១៧ឆ្នាំ និងកូនទី២ ឈ្មោះ [redacted] **បញ្ញាពណ៌** ភេទស្រី អាយុ ០៦ឆ្នាំ ។

-ប្រគល់ឲ្យចុងចម្លើយមានសិទ្ធិគ្រប់គ្រងលើទ្រព្យរួម ។

២-ការពន្យល់ត្រួសៗអំពីរឿងក្តី៖

កាលពីឆ្នាំ២០០២ ដើមចោទឈ្មោះ [redacted] **អាន** និងចុងចម្លើយឈ្មោះ [redacted] **ផល្លា** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ៤៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០០៨ ត្រឹមត្រូវតាមច្បាប់នៅអត្រានុកូលដ្ឋានសង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ក្នុងរយៈពេលរស់ជាមួយគ្នាមានកូនពីរនាក់ ១.ឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស អាយុ១៧ឆ្នាំ និងកូនទី២ ឈ្មោះ [redacted] **បញ្ញាពណ៌** ភេទស្រី អាយុ ០៦ឆ្នាំ។ក្នុងពេលរួមរស់ជាមួយគ្នាកន្លងមកខ្លួននិងចុងចម្លើយឈ្មោះ [redacted] **ផល្លា** ការរស់នៅកន្លងមកជាប្តីប្រពន្ធមិនសូវចុះសម្រុងនឹងគ្នា មិនយល់ចិត្តគ្នានិងមានរឿងរ៉ាវជាច្រើនទៀត ដែលជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀតបាន ដើមចោទក៏បានសម្រេចចិត្តដាក់ពាក្យបណ្តឹងចូលមកតុលាការតែម្តង ។

II. អង្គហេតុដែលជាមូលហេតុនៃការទាមទារ:

មូលហេតុដែលដើមចោទប្តឹងសុំផ្តាច់ចំណងអាពាហ៍ពិពាហ៍ ដោយសារតែរស់នៅមិនចុះសម្រុងនឹងគ្នា ដែលជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនា ក្នុងការរួមរស់ជាប្តីប្រពន្ធតទៅទៀតបាន ។

៣. សាលក្រមដែលទាមទារដោយដើមចោទ:

១.សុំផ្តាច់ចំណងអាពាហ៍ពិពាហ៍ពីប្រពន្ធឈ្មោះ [redacted] ផល្លា តាមច្បាប់ ។

២.ប្រគល់ឲ្យចុងចម្លើយមានសិទ្ធិគ្រប់គ្រងកូនចំនួន២នាក់ ទី១ ឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស អាយុ១៧ឆ្នាំ និងកូនទី២ ឈ្មោះ [redacted] **បញ្ញាពណ៌** ភេទស្រី អាយុ ០៦ឆ្នាំ ។

៣.ប្រគល់ឲ្យចុងចម្លើយមានសិទ្ធិគ្រប់គ្រងលើទ្រព្យរួម ។

III. ការអះអាងរបស់ដើមចោទ:

ដើមចោទឈ្មោះ [redacted] **អាន** បានអះអាងថា ខ្លួននិងចុងចម្លើយឈ្មោះ [redacted] **ផល្លា** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីនៅឆ្នាំ២០០២ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ៤៤ ចុះថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ២០០៨ ត្រឹមត្រូវតាមច្បាប់នៅអត្រានុកូលដ្ឋានសង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ក្នុងរយៈពេលរស់ជាមួយគ្នាមានកូនពីរនាក់ ១.ឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស អាយុ១៧ឆ្នាំ និងកូនទី២ ឈ្មោះ [redacted] **បញ្ញាពណ៌** ភេទស្រី អាយុ ០៦ឆ្នាំ។ ក្នុងពេលរួមរស់ជាមួយគ្នាកន្លងមក ខ្លួននិងចុងចម្លើយឈ្មោះ [redacted] **ផល្លា** តែងតែមានរឿងរកាំរកូសនឹងគ្នាជាញឹកញាប់ មិនយល់ចិត្តគ្នានិងមានរឿងរ៉ាវជាច្រើនទៀតដែលជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបានឡើយ។ដូចនេះ ទើបសម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការចេញសាលក្រមដូចខាងក្រោម៖

១.សុំផ្តាច់ចំណងអាពាហ៍ពិពាហ៍ពីប្រពន្ធឈ្មោះ [redacted] ផល្លា តាមច្បាប់ ។

២.ប្រគល់ឲ្យចុងចម្លើយមានសិទ្ធិគ្រប់គ្រងកូនចំនួន២នាក់ ទី១ ឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស អាយុ១៧ឆ្នាំ និងកូនទី២ ឈ្មោះ [redacted] **បញ្ញាពណ៌** ភេទស្រី អាយុ ០៦ឆ្នាំ ។

៣.ប្រគល់ឲ្យចុងចម្លើយមានសិទ្ធិគ្រប់គ្រងលើទ្រព្យរួម ។



Scanned with CamScanner

IV.សេចក្តីថ្លែងការណ៍របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទនៅដំណាក់កាលស្តីពីការធ្វើនីតិវិធីត្រៀម និងនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់បានថ្លែងការណ៍ថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] **អាន** និងចុងចម្លើយឈ្មោះ [redacted] **ផល្លា** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីនៅឆ្នាំ២០០២ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ៤៤ ចុះថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ២០០៨ ត្រឹមត្រូវតាមច្បាប់នៅអគ្រានុកូលដ្ឋានសង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ក្នុងរយៈពេលរស់ជាមួយគ្នាមានកូនពីរ នាក់ ១.ឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស អាយុ១៧ឆ្នាំ និងកូនទី២ ឈ្មោះ [redacted] **បញ្ញាពណ៌** ភេទស្រី អាយុ ០៦ឆ្នាំ និងមានទ្រព្យរួមដី៤កន្លែងក្នុងការរស់ជាមួយគ្នាកន្លងមកតែងតែមានរឿងរកាំរកូសនឹងគ្នាជាញឹកញាប់ រស់នៅមិនយល់ចិត្តគ្នារទៅវិញទៅមក ដែលជាហេតុធ្វើឱ្យកូនក្តីខ្លួនអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀតបានឡើយ ។ ដូចនេះ ស្នើសុំឱ្យតុលាការចេញសាលក្រមដល់កូនក្តីខ្លួនដែលមានខ្លឹមសារដូចខាងក្រោម៖

១.សុំផ្តាច់ចំណងអាពាហ៍ពិពាហ៍ពីប្រពន្ធឈ្មោះ [redacted] **ផល្លា** តាមច្បាប់ ។

២.សុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស អាយុ១៧ឆ្នាំ ។

៣.ការបែងចែកទ្រព្យរួមមាន៖

ក/.ដីមានទំហំ ៣៤១ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចនវត្ថុលេខ: ០៨០១១៩០១-០៥៨៥ លេខក្បាលដី ៥៨៥ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៥ មានទីតាំងស្ថិតនៅភូមិក្រពើទ្រោម សង្កាត់រលួស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កូនក្តីរបស់ខ្លួនស្នើសុំគ្រប់គ្រង។

ខ/.ដីមានទំហំ ១៤០៤ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចនវត្ថុលេខ: ២១១០០៨០៦-១០៣៦ លេខក្បាលដី ១០៣៦ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៣ មានទីតាំងស្ថិតនៅភូមិព្រៃផ្អាវ សង្កាត់រនាម ស្រុកទ្រាំង ខេត្តតាកែវ ។

គ/.ដីមានទំហំ ២១៥២ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចនវត្ថុលេខ: ២១១០០៨០៦-១៦៩៩ លេខក្បាលដី ១៦៩៩ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៣ មានទីតាំងស្ថិតនៅភូមិព្រៃផ្អាវ សង្កាត់រនាម ស្រុកទ្រាំង ខេត្តតាកែវ ។

ឃ/.ដីមានទំហំ ៤៧៩ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចនវត្ថុលេខ: ០៨១១០៣០៣-០២២៩ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០១៨ មានទីតាំងស្ថិតនៅព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រគល់ទៅឱ្យចុងចម្លើយគ្រប់គ្រង ។ ចំពោះកូនទាំងពីនាក់ កូនក្តីរបស់ខ្លួនស្នើសុំសិទ្ធិអំណាចមេបាលើកូនមួយនាក់ ឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស កើតឆ្នាំ២០០៥ រីឯកូនឈ្មោះ [redacted] **បញ្ញាពណ៌** ភេទស្រី កើតឆ្នាំ២០១៥ ប្រគល់ឱ្យចុងចម្លើយគ្រប់គ្រង ។

V. ការអះអាងរបស់ចុងចម្លើយ:

-ចុងចម្លើយឈ្មោះ [redacted] **ផល្លា** បានអះអាងថា: នៅដំណាក់កាលធ្វើនីតិវិធីត្រៀម និងនីតិវិធីសម្រាប់ការទាញដោយផ្ទាល់មាត់ ការលែងលះ ខ្លួនបានឯកភាព ការសុំសិទ្ធិគ្រប់គ្រងកូនប្រុសបងឯកភាព ចំពោះការបែងចែកទ្រព្យរួមមានដី៤កន្លែងខ្លួនយល់ព្រមឱ្យដីមួយកន្លែងនៅខេត្តតាកែវទៅឱ្យដើមចោទជ្រើសរើសយកបានពីព្រោះដីនៅខេត្តតាកែវមាន២កន្លែង ចំណែកដី២កន្លែងទៀតខ្លួនមិនយល់ព្រមឱ្យទេ ដីនេះជាកេរ្តិ៍របស់ម្តាយ ចំពោះការស្នើសុំគ្រប់គ្រងកូនប្រុសឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស កើតឆ្នាំ២០០៥ ឯកភាព ។

-ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **ខេមរីន** ភេទប្រុស អាយុ ៤៦ឆ្នាំ បានថ្លែងការណ៍បញ្ជាក់នៅនីតិវិធីសម្រាប់ការទាញដោយផ្ទាល់មាត់ថា ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១១៩០១-០៥៨៥មានទីតាំងស្ថិតនៅភូមិក្រពើទ្រោម សង្កាត់ រលួស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល គឺជាដីកេរ្តិ៍របស់ម្តាយខ្លួន ហើយបានចែកឱ្យឈ្មោះ [redacted] **ផល្លា** ត្រូវជាកូនបង្កើត ។

-ដើមចោទឈ្មោះ [redacted] **រឿន** បានធ្វើសេចក្តីថ្លែងការណ៍តបវិញថា ការអះអាងរបស់សាក្សីឈ្មោះ [redacted] **ខែមរីន** បញ្ជាក់នៅនីតិវិធីសម្រាប់ការទាញដោយផ្ទាល់មាត់ថា ដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៨០១១៩០១-០៥៨៥ មានទីតាំងស្ថិតនៅភូមិក្រពើទ្រោម សង្កាត់ វល្លេស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល គឺជាដីកេរ្តិ៍របស់ម្តាយមិនត្រឹមត្រូវទេ ខ្លួនបានទិញពីម្តាយក្មេក ហើយលិខិតទិញលក់គឺចុងចម្លើយជាអ្នកទុកដាក់ ខ្លួនចុះចេញមកតែខ្លួនទទេ មិនមានយកអ្វីមកតាមខ្លួនទេ ។ ដូចនេះ ខ្លួនស្នើសុំឱ្យតុលាការបែងចែកទ្រព្យរួមដែលមានដីចំនួន៤កន្លែង ប៉ុន្តែខ្លួនសុំយកដីតែមួយកន្លែងទេ ៣កន្លែងទៀតទុកឱ្យចុងចម្លើយ ។

VI-សេចក្តីថ្លែងការណ៍លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយនៅដំណាក់កាលស្តីពីការធ្វើនីតិវិធីត្រៀម និងនីតិវិធីសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់បានថ្លែងការណ៍ដូចខាងក្រោម៖

I-អំពីអង្គហេតុ៖

កូនក្តីយើងខ្ញុំមានឈ្មោះ [redacted] **ផល្លា** បានរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទឈ្មោះ [redacted] **រឿន** នៅថ្ងៃទី០៨ ខែ មីនា ឆ្នាំ២០០២ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ៤៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០០៨ ត្រឹមត្រូវតាមច្បាប់ ។ ក្រោយពីរៀបចុះសំបុត្រអាពាហ៍ពិពាហ៍រួចមកដើមចោទ និងចុងចម្លើយបានរស់នៅជាមួយគ្នាយ៉ាងមានសុភមង្គលរហូត បានបង្កើតកូនប្រុសស្រី ចំនួន ០២នាក់ គឺកូនប្រុសឈ្មោះ [redacted] **ឆាយហាក់** និងកូនស្រីឈ្មោះ [redacted] **បញ្ញាពណ៌** និងទ្រព្យរួមមួយចំនួនទៀត។ក្រោយពីរៀបអាពាហ៍ពិពាហ៍រួចមកការរួមរស់ជាមួយគ្នារវាងចុងចម្លើយ និងដើមចោទមានភាពល្អកល្អើន និងមានសុភមង្គលនឹងគ្នា ប៉ុន្តែរយះពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ចុងចម្លើយដែលជាកូនក្តីរបស់យើងខ្ញុំ និងប្តីមានការមិនចុះសម្រុងគ្នានិងទំនាស់ពាក្យសម្តីជាញឹកញាប់ ដោយភាគីដើមចោទគិតតែពីដើរ ផឹកស៊ីសប្បាយមិនគិតគូរពីគ្រួសារឡើយ។ លើសពីនេះ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ដើមចោទបានចុះ ចោលពីផ្ទះ ដោយពុំបានផ្តល់ដំណឹងឱ្យកូនក្តីយើងខ្ញុំបានដឹងអស់រយះពេលជាច្រើនខែ ។

នៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២១ សាលាដំបូងខេត្តកណ្តាល បានចេញដីកាកោះកូនក្តីយើងខ្ញុំសម្រាប់នីតិវិធីត្រៀមទាញហេតុផលលើកទី១ ហើយចំពោះមុខចៅក្រម និងក្រឡាបញ្ជី កូនក្តីយើងខ្ញុំនិងដើមចោទបានព្រម ព្រៀងគ្នាក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍និងបែងចែកកូនទាំងពីរ ដោយកូនក្តីរបស់យើងខ្ញុំយល់ព្រមទទួលយកកូនស្រី ចំណែកដើមចោទទទួលយកកូនប្រុស។ប៉ុន្តែដើមចោទបានស្នើសុំដីមួយកន្លែងក្នុងចំណោយទ្រព្យរួមទាំងអស់ដោយលើកហេតុផលថា ទុកសម្រាប់កូនប្រុសឈ្មោះ សហេង ឆាយហាក់ ទៅថ្ងៃអនាគត។ តែផ្ទុយមកវិញ កូនក្តីយើងខ្ញុំមិនព្រមទទួលយកនូវការស្នើសុំពីភាគីដើមចោទនោះទេ ។

II-អំពីអង្គហេតុ៖

-មាត្រា៩៧៨ចំណុច ង "មូលហេតុនៃការលែងលះ" ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ។

-មាត្រា៩៧២ចំណុច ខ "ទ្រព្យដោយឡែក "ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្មសន្តតិកម្មអច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

III-សេចក្តីសន្និដ្ឋាន៖

១.យោងតាមរយៈអង្គហេតុ និងអង្គច្បាប់ខាងលើ ឃើញថាកូនក្តីយើងខ្ញុំពិតជាមិនអាចទទួលយកមិនបាននូវអំពើដែលដើមចោទជាប្តីធ្វើបានដាក់ខ្លួននោះទេ ដោយសារតែមិនបំពេញតួនាទីជាប្តី និងបានចុះចេញពីផ្ទះដោយពុំបានជូនដំណឹងមកកូនក្តីយើងខ្ញុំឡើយ ដែលផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។ លើសពីនេះទៅទៀតចំពោះការស្នើសុំរបស់ខាងដើមចោទក្នុងការទាមទារដីមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៨ ១១០៣០៣០-០២២៩ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៨កូនក្តីយើងខ្ញុំមិនយល់ព្រមជាដាច់ខាត ដោយហេតុថា ដីដែល



Scanned with CamScanner

មានឈ្មោះជាទ្រព្យរួមនោះ គឺជាទ្រព្យដោយឡែក (លើសពីនេះទៅទៀតក៏មានការបញ្ជាក់ច្បាស់លាស់ផងដែរពីចៅសង្កាត់រលួសឈ្មោះ [redacted] **ហ៊ន** ថា កូនក្តីយើងខ្ញុំពិតជាទទួលបានដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:០៨១១០៣០៣-០២២៩ ចុះថ្ងៃទី១៩ ខែមីនាឆ្នាំ២០១៨នោះពីម្តាយឈ្មោះ [redacted] សារឿន ពិតប្រាកដមែនដោយសារតែការយល់ឃើញថា ដើមចោទ គឺជាមេគ្រួសារ ជាប្តីស្របច្បាប់ មានទំនុកចិត្តចំពោះគ្នាទៅវិញទៅមក ហើយខ្លួនជាស្រីដែលពុំបានរៀនសូត្រជ្រៅជ្រះ ថែមទាំងមិនចេះអក្សរទៀតផងនោះ រាល់កិច្ចការចុះបញ្ជីធ្វើប័ណ្ណកម្មសិទ្ធិ គឺឈ្មោះ [redacted] **រតន** តែប៉ុណ្ណោះជាអ្នកចាត់ចែងធ្វើកិច្ចការងារនេះ ។

IV-សំណូមពរ៖

សរុបសេចក្តីមកផ្អែកតាមអង្គហេតុនិងអង្គច្បាប់ ដូចបានរៀបរាប់ខាងលើ យើងខ្ញុំជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] **ផល្លា** ស្នើសុំឲ្យតុលាការមេត្តាសម្រេច៖

១-ផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងចុងចម្លើយឈ្មោះ [redacted] **ផល្លា** និងដើមចោទឈ្មោះ [redacted] **រតន** ។

២-ផ្តល់នូវអំណាចមេបាចំពោះកូនស្រី ឈ្មោះ [redacted] **បញ្ញាពណ៌** មកឲ្យចុងចម្លើយ ។

៣-ទាមទារសិទ្ធលើអចលនទ្រព្យទាំង៤មានដូចជា៖

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:០៨០១១៩០១-០៥៨៥ចុះថ្ងៃទី១៤ខែវិច្ឆិកាឆ្នាំ២០០៥ ។

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ២១១០០៨០៦-១០៣៦ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៣ ។

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:២១១០០៨០៦-១៦៩៩ ចុះថ្ងៃទី៣០ខែតុលាឆ្នាំ២០១៣ ។

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:០៨១១០៣០៣-០២២៩ ចុះថ្ងៃទី១៩ខែមីនាឆ្នាំ២០១៨ មកឲ្យចុងចម្លើយឈ្មោះ ចេក ផល្លា ។

VI. ចំណុចវិវាទ និងចំណុចគ្មានវិវាទ

១. ចំណុចវិវាទ: ដី៤កន្លែង ។

VII. ចំណុចគ្មានវិវាទ :

ឯកភាពលែងលះ ចំពោះការសុំគ្រប់គ្រងកូនឈ្មោះ [redacted] **បញ្ញាពណ៌** កើតឆ្នាំ ២០១៥ ខ្លួនបានឯកភាពឲ្យចុងចម្លើយគ្រប់គ្រង និងកូនឈ្មោះ [redacted] **ឆាយហាក់** កើតឆ្នាំ២០០៥ ឲ្យដើមចោទគ្រប់គ្រង ។

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីឲ្យដើមចោទ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីឲ្យចុងចម្លើយ

ក្រោយពីថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.ក្រោយពីបានធ្វើការសាកសួរភាគីដើមចោទធ្វើការផ្សះផ្សា និងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនិងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ តុលាការយល់ឃើញថា:គូភាគីពិតជាបានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីពិតប្រាកដមែន ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់នៅមន្ត្រីអត្រានុកូលដ្ឋានដែលមានលេខ:៤៤និងសៀវភៅអាពាហ៍ពិពាហ៍លេខ:០១/២០០៨ ចុះថ្ងៃទី០៩ខែឧសភាឆ្នាំ២០០៨ ពិតប្រាកដមែន ។

២.ដើមចោទនិងចុងចម្លើយបានថ្លែងថា ខ្លួនអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាទៅទៀតបាន ដោយសារតែការរស់នៅជាមួយគ្នាកន្លងមកពុំសូវចុះសម្រុងគ្នា មិនយល់ចិត្តគ្នា ហេតុទាំងអស់នេះ បង្ហាញថា

ប្ដីប្រពន្ធលែងមានករណីរួមរស់នឹងគ្នា លែងសហការគ្នា លែងសង្គ្រោះគ្នាទៅវិញទៅមក ជាមូលហេតុនៃការលែងលះគ្នាបាន ស្របតាមមាត្រា ៩៧៨ ចំណុច ង នៃក្រមរដ្ឋប្បវេណី ។

៣.ភាគីចុងចម្លើយបានដាក់ឯកសារជាភស្តុតាងរួមមាន:

៣.១.សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ:៩៤ និងសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០០៨ ចុះថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ២០០៨ (មួយច្បាប់ថតចម្លង) ។

៣.២.ដីមានទំហំ ៣៤១ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:០៨០១១៩០១ ០៥៨៥ លេខក្បាលដី ៥៨៥ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៥ មានទីតាំងស្ថិតនៅភូមិក្រពើទ្រោម សង្កាត់រលួស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

៣.៣.ដីមានទំហំ ១៤០៤ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ២១១០០៨០៦-១០៣៦ លេខក្បាលដី ១០៣៦ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៣ មានទីតាំងស្ថិតនៅភូមិព្រៃផ្គាវ សង្កាត់រនាម ស្រុកទ្រាំង ខេត្តតាកែវ ។

៣.៤.ដីមានទំហំ ២១៥២ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ២១១០០៨០៦-១៦៩៩ លេខក្បាលដី ១៦៩៩ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៣ មានទីតាំងស្ថិតនៅភូមិព្រៃផ្គាវ សង្កាត់រនាម ស្រុក ទ្រាំង ខេត្តតាកែវ ។

៣.៥.ដីមានទំហំ៤៧៩ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:០៨១១០៣ ០៣-០២២៩ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០១៨ មានទីតាំងស្ថិតនៅព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្ត កណ្ដាល ។

៣.៦.សំបុត្រកំណើតចុះថ្ងៃទី៣១ខែកក្កដាឆ្នាំ២០០៦របស់ឈ្មោះ សហេង ឆាយហាក់(មួយច្បាប់ថតចម្លង) ។

៣.៧.សំបុត្រកំណើតចុះថ្ងៃទី២០ខែសីហាឆ្នាំ២០១៥ របស់ឈ្មោះ សរឆាយ បញ្ចបណ៍(មួយច្បាប់ថតចម្លង) ។

៣.៨.សៀវភៅស្នាក់នៅ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ (មួយច្បាប់ថតចម្លង) ។

៣.៩.ពាក្យបណ្ដឹងតម្កល់ទុក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ។

៣.៥.ចុងចម្លើយបានអះអាងថា:ភស្តុតាងដែលបានដាក់ជូននេះបានថតចម្លងចេញពីច្បាប់ដើមត្រឹមត្រូវ មិនក្លែងបន្លំអ្វីឡើយ និងធានាខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើលិខិតដាក់ជូនទាំងអស់នេះមានការក្លែងបន្លំផ្ទុយពីច្បាប់ដើម ។

៤.ការបែងចែកទ្រព្យរួមមានដី៤កន្លែង៖

ក/.ដីមានទំហំ ៣៤១ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៨០១១ ៩០១-០៥៨៥ លេខក្បាលដី ៥៨៥ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៥ មានទីតាំងស្ថិតនៅភូមិក្រពើទ្រោម សង្កាត់រលួស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

ខ/.ដីមានទំហំ១៤០៤ម៉ែត្រការ៉េដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:២១១០០៨០៦ -១០៣៦ លេខក្បាលដី ១០៣៦ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១៣ មានទីតាំងស្ថិតនៅភូមិព្រៃផ្គាវ សង្កាត់រនាម ស្រុកទ្រាំង ខេត្តតាកែវ ។

គ/.ដីមានទំហំ២១៥២ម៉ែត្រការ៉េដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ២១១០០ ៨០៦-១៦៩៩ លេខក្បាលដី ១៦៩៩ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៣ មានទីតាំងស្ថិតនៅភូមិព្រៃផ្គាវ សង្កាត់រនាម ស្រុកទ្រាំង ខេត្តតាកែវ ។



Scanned with CamScanner

ឃ/.ដីមានទំហំ ៤៧៩ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ០៨១១០៣០៣-០២២៩ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០១៨ មានទីតាំងស្ថិតនៅព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ។ តាមការពិនិត្យភស្តុតាងទ្រព្យសម្បត្តិរបស់គូភាគីពិតឃើញថា មានដី ៤កន្លែង ដោយចាត់ទុកថា ជាទ្រព្យរួម តែដោយសារដើមបណ្តឹងបានលះបង់លើការបែងចែកជាពីរចំណែកស្មើៗគ្នា សុខចិត្ត ទទួលយកដីតែ ១កន្លែង ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៨០១១៩០១-០៥៨៥ បាន ប្រគល់ដី ៣កន្លែងទៀត ទៅឱ្យចុងចម្លើយ ដូចនេះ តុលាការ គប្បីពិចារណាសម្រេចតាមការស្នើសុំរបស់ដើមចោទ ។

៥.ក្នុងពេលលែងលះគ្នានេះ ខាងដើមចោទនិងចុងចម្លើយបានឯកភាពគ្នាចំពោះអំណាចមេបាលើកូនឈ្មោះ [redacted] **ឆាយហាក់** ឈ្មោះ [redacted] **បញ្ញាពណ៌** ម្យ៉ាងទៀត តុលាការឃើញថា ដើមចោទមានស្ថានភាពរស់នៅល្អដូចគ្នា មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹម និងអប់រំកូនៗបានល្អក្នុងសង្គម ។ ដូចនេះ តុលាការពិចារ ណានិងធ្វើការសម្រេចទៅតាមការឯកភាពគ្នារបស់គូភាគី ។

៦. រឿងក្តីនេះតុលាការអស់លទ្ធភាពក្នុងការផ្សះផ្សាហើយ ។

៧.ផ្អែកតាមសំអាងហេតុខាងលើនេះ ការទាមទាររបស់ដើមចោទមានមូលដ្ឋានសំអាងត្រឹមត្រូវតាមច្បាប់ គប្បីតុលាការទទួលស្គាល់នូវការទាមទារនេះ ។

៨.ប្រាក់ប្រដាប់ក្តីអនុលោមតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ឱ្យដើមចោទទទួលបន្ទុកបង់ ប្រាក់ប្រដាប់ក្តី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ឱ្យដើមចោទឈ្មោះ [redacted] **រាន** លែងលះ ពីចុងចម្លើយឈ្មោះ [redacted] **ផល្លា** ។

២-ឱ្យដើមចោទឈ្មោះ [redacted] **រាន** ជាអ្នកមានអំណាចមេបាលើកូនបងឈ្មោះ [redacted] **ឆាយហាក់** ភេទប្រុស កើតថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៥ ។

៣-ឱ្យចុងចម្លើយឈ្មោះ [redacted] **ផល្លា** ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **បញ្ញាពណ៌** ភេទស្រី កើតថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៥ ។

៤-ទុកសិទ្ធិឱ្យឪពុកនិងម្តាយសួរសុខទុក្ខកូននិងយកកូនទៅលេងបានដោយពិភាក្សាអ្នកមានអំណាចមេបាព្រមទាំងកូនមិនប៉ះពាល់ផលប្រយោជន៍របស់កូនដោយ១សប្តាហ៍ម្តងនិងកំណត់យកថ្ងៃសៅរ៍ រឺថ្ងៃអាទិត្យ ចាប់ពីម៉ោង ៧ព្រឹក ដល់ម៉ោង១៧ល្ងាច ទីតាំងប្រគល់និងទទួលទីកន្លែងស្នាក់នៅរបស់កូន ។

**៥**-បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] **រាន**បង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនមួយនាក់ឈ្មោះ [redacted] **បញ្ញាពណ៌** ក្នុង១ខែ ២០០០០០ (ម្ភៃម៉ឺនរៀល)រហូតដល់នីតិភាព ។

**៦**-ការបែងចែកទ្រព្យរួមឱ្យគូភាគីដូចខាងក្រោម៖

ក/.ដីមានទំហំ៣៤១ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៨០១១៩០១-០៥៨៥លេខក្បាលដី ៥៨៥ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៥ មានទីតាំងស្ថិតនៅភូមិក្រពើទ្រោម សង្កាត់រលួស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រគល់ទៅឱ្យដើមចោទគ្រប់គ្រង ។

ខ/.ដីមានទំហំ ១៤០៤ ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ២១១០០៨០៦-១០៣៦ លេខក្បាលដី ១០៣៦ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១៣ មានទីតាំងស្ថិតនៅភូមិព្រៃផ្លាវ សង្កាត់ រនាម ស្រុកទ្រាំង ខេត្តតាកែវ ។

គ/.ដីមានទំហំ ២១៥២ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:២១១០០



Scanned with CamScanner

៨០៦-១៦៩៩ លេខក្បាលដី ១៦៩៩ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៣ មានទីតាំងស្ថិតនៅភូមិព្រៃផ្អាវ សង្កាត់រនាម ស្រុកទ្រាំង ខេត្តតាកែវ ។

ឃ/.ដីមានទំហំ៤៧៩ ម៉ែត្រការ៉េដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ ០៨១១០ ៣០៣-០២២៩ ចុះថ្ងៃទី១៨ ខែ មីនា ឆ្នាំ ២០១៨ មានទីតាំងស្ថិតនៅព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រគល់ទៅឲ្យចុងចម្លើយគ្រប់គ្រង ។

៧-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែ តុលា ឆ្នាំ២០២១ ចំពោះមុខដើមចោទ និងកំបាំងចុងចម្លើយ ។

ទុកសិទ្ធិ ប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃពុធ ១៤កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កណ្ដាល,ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

"បានចម្លងត្រឹមត្រូវតាមសាលក្រមដើម"

កណ្ដាល, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]